**បក្សប្រជាជនបដិវត្តកម្ពុជា**

គណៈកម្មាធិការមជ្ឈិម ភ្នំពេញ, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៨៦

លេខ : ១៨ ស.ស.រ.ម.ឈ

# សេចក្តីកំណត់
# អំពីភារកិច្ច សិទ្ធិអំណាច និងអង្គភាពចាត់តាំង
# របស់គណៈស្រាវជ្រាវប្រវត្តិសាស្រ្តបក្ស

- យោងតាមសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតបក្សលើកទី V ស្តីពីការស្រាវជ្រាវ ចងក្រងប្រវត្តិសាស្រ្តបក្សប្រជាជនបដិវត្តកម្ពុជា
- យោងតាមសេចក្តីសម្រេចបង្កើតគណៈស្រាវជ្រាវប្រវត្តិសាស្រ្តបក្សរបស់ការិយាល័យនយោបាយមជ្ឈិមបក្ស លេខ ១៧ ស.ស.រ.ម.ឈ ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ១៩៨៦

## ការិយាល័យនយោបាយមជ្ឈិមបក្សសម្រេច:

ប្រការ១ : គណៈស្រាវជ្រាវប្រវត្តិសាស្រ្តបក្ស អនុវត្តតាមភារកិច្ច និងសិទ្ធិអំណាចជាក់ស្តែង ដូចខាងក្រោម :

**ក - គណៈស្រាវជ្រាវប្រវត្តិសាស្រ្តបក្ស មានភារកិច្ច :**

- ស្រាវជ្រាវ ចងក្រងការវិវត្តន៍ឡើងនៃប្រវត្តិសាស្រ្តបក្សក្នុងរយៈពេលកន្លងមក គឺគិតចាប់តាំងពីថ្ងៃបង្កើតបក្សរហូតមកដល់បច្ចុប្បន្ន និងទៅអនាគត។ ក្នុងការចងក្រងសៀវភៅប្រវត្តិសាស្រ្ត គឺធ្វើយ៉ាងណាសម្រេចឲ្យបានបណ្តាសំណូមពរជាមូលដ្ឋាន ដូចតទៅ :

១- ការអនុវត្តលទ្ធិម៉ាក្ស-លេនីន សមស្របនឹងលក្ខណៈជាក់ស្តែងរបស់កម្ពុជា សម្តែងឡើងនូវគោលមាគ៌ានយោបាយរបស់បក្ស ក្នុងដំណាក់កាលនីមួយៗ និងចាប់តាំងពីដំណាក់កាលកសាងបក្សរហូតមក... ។

២- បណ្តាចលនាបដិវត្តន៍របស់មហាជនប្រជាជន អនុវត្តនូវគោលមាគ៌ា នយោបាយរបស់បក្ស ។

៣- បណ្តាគោលមាគ៌ា និងវិធានការកសាងបក្ស គឺដើម្បីអនុវត្តភារកិច្ចនយោបាយដែលបក្សបានដាក់ចេញ ។ សំខាន់ក្តាប់ឲ្យបានសកម្មភាព និងការចាត់តាំងរបស់បក្សនៅមូលដ្ឋាន ខេត្ត ស្រុក ឃុំ... ។

៤- បណ្តាបទពិសោធន៍អំពីការដឹកនាំបដិវត្តរបស់បក្ស ក្នុងដំណាក់កាលនីមួយៗ និងក្នុងការរីកចម្រើនវិវត្តន៍ឡើងរបស់បក្ស ។

៥- វិភាគទៅតាមដំណាក់កាលនីមួយៗ ដែលបក្សបានឆ្លងកាត់កន្លងមក ដើម្បីដកជាមេរៀន បទពិសោធន៍ ក្នុងការងារកសាងបក្ស សំដៅពង្រីកបានគុណសម្បត្តិ និងជម្នះបាននូវគុណវិបត្តិ បម្រើឲ្យការកសាងបក្ស ត្រឹមត្រូវចំពោះមុខ ក៏ដូចជាទៅអនាគត ។

៦- ចំណងយុទ្ធសាមគ្គីភាពដ៏ស្អិតរមួត រវាងកម្ពុជា វៀតណាម ឡាវ ពិសេសចំណងយុទ្ធសាមគ្គីភាពកម្ពុជា វៀតណាម ជាកត្តាស្លាប់រស់ និងជាប្រវត្តិសាស្រ្តដ៏យូរលង់ ។

**ខ - គណៈស្រាវជ្រាវប្រវត្តិសាស្ត្របក្ស មានសិទ្ធិ :**

១- ទំនាក់ទំនងជាមួយរាល់ស្ថាប័នរបស់បក្ស រដ្ឋ... ក្រសួង មន្ទីរ ខេត្ត ក្រុង និងគ្រប់ទីកន្លែង ដែលចាំបាច់ ដើម្បីស្វែងរកប្រមែប្រមូលបណ្ដាឯកសារដែលទាក់ទងទៅនឹងប្រវត្តិសាស្ត្ររបស់បក្ស ។ ប្រមែប្រមូលបណ្ដាឯកសារ គោលការណ៍ នយោបាយ របស់បក្ស រាល់សារាចរ សេចក្ដីសម្រេចចិត្តរបស់មជ្ឈិមបក្ស ។

២- ចុះស្រាវជ្រាវកត់ត្រាឡើងវិញរាល់ចលនារបស់មហាជនក្នុងការអនុវត្តន៍នូវគោលមាគ៌ា នយោបាយរបស់បក្ស ។

៣- ចុះស្រាវជ្រាវរាល់សកម្មភាព និងការចាត់តាំងរបស់បក្សនៅគ្រប់មូលដ្ឋាន ។

៤- ចុះជួបប្រាស្រ័យផ្ទាល់ ឬអញ្ជើញកម្មាភិបាល បក្ខជនចាស់ៗ ថ្នាក់ដឹកនាំបក្ស និងរដ្ឋដែលបានរួមសកម្មភាពក្នុងបក្ស និងក្នុងចលនាបដិវត្តន៍ ក្នុងដំណាក់កាលនីមួយៗ ដើម្បីដកស្រង់ពត៌មាន ចងក្រងជាសំណុំឯកសារ ។

៥- បើកវគ្គសិក្ខាសាលា ពិភាក្សាពីសៀវភៅប្រវត្តិសាស្ត្រព្រាងរបស់បក្ស... ។

៦- សុំគោលនយោបាយពីគណៈលេខាមជ្ឈិមបក្ស ដើម្បីទំនាក់ទំនងផ្ទាល់ជាមួយបណ្ដាបក្សជាបងប្អូននៅក្រៅប្រទេស ដែលមានឯកសារទាក់ទងដល់ប្រវត្តិសាស្ត្ររបស់បក្សប្រជាជនបដិវត្តកម្ពុជា ។

៧- រក្សា ការពារ និងគ្រប់គ្រងរាល់បេតិកភណ្ឌបក្ស ជាកេរ្តិ៍ដំណែល តឹកតាងបញ្ជាក់នូវរាល់សកម្មភាព និងប្រវត្តិសាស្ត្របក្ស ដូចជា មូលដ្ឋានបដិវត្តន៍ ជំរុំ ទីកន្លែង លំនៅ សំភារៈឧបករណ៍ ឯកសារ ប្រដាប់ប្រដាប្រើប្រាស់របស់បុគ្គល និងសមូហភាព ។ល ។

<u>**ប្រការ២**</u> : អំពីអង្គការចាត់តាំង និងក្របខ័ណ្ឌរបស់ស្ថាប័ន គណៈស្រាវជ្រាវប្រវត្តិសាស្ត្របក្ស :

**ក- គណៈស្រាវជ្រាវប្រវត្តិសាស្ត្របក្ស រួមមានក្បាលម៉ាស៊ីនដឹកនាំ :**

ប្រធាន : ជាអ្នកទទួលខុសត្រូវរួម សំខាន់គឺដឹកនាំ ណែនាំ រាល់ការងាររបស់គណៈ ។

អនុប្រធាន : ជាអ្នកជំនួយការឲ្យសមមិត្តប្រធាន ដឹកនាំបណ្ដាផ្នែកជំនាញ និងទទួលបន្ទុកបណ្ដាផ្នែកដែលបានប្រគល់ឲ្យ ។

**ខ-** គណៈស្រាវជ្រាវប្រវត្តិសាស្ត្របក្ស ចាត់តាំងក្បាលម៉ាស៊ីនជំនួយការងារឲ្យបានសមស្រប និងមានប្រសិទ្ធភាព ដើម្បីអនុវត្តភារកិច្ច សិទ្ធិអំណាច ដូចបានកំណត់ខាងលើ រួមមាន មន្ទីរ និងនាយកដ្ឋានមួយចំនួនអង្គភាពចំណុះគណៈស្រាវជ្រាវប្រវត្តិសាស្ត្របក្ស ។ ចំពោះមុខដើម្បីដំណើរការបានប្រសិទ្ធិភាពត្រូវមាន ៖

- មន្ទីរ "រដ្ឋបាល គ្រប់គ្រង គណនេយ្យ ជីវភាព យានជំនិះ"
- នាយកដ្ឋានស្រាវជ្រាវ និងបូកសរុប "រួមមានស្រាវជ្រាវប្រវត្តិសាស្ត្រតាមរយៈពេលនីមួយៗ បកប្រែភាសា រួមមានភាសាវៀតណាម បារាំង អង់គ្លេស សូវៀត ។ល។ ផ្នែកបូកសរុប និង ព្រាងឯកសារ" ។
- នាយកដ្ឋានសំណុំរឿងឯកសារ "រួមមានផ្នែក តម្កល់ឯកសារ" ។ល ។
- ក្របខណ្ឌក្បាលម៉ាស៊ីនចាត់តាំង ជំនួយការរបស់គណៈស្រាវជ្រាវប្រវត្តិសាស្ត្របក្សអាស្រ័យដោយគណៈស្រាវជ្រាវប្រវត្តិសាស្ត្របក្ស ពិភាក្សាឯកភាពជាមួយគណៈចាត់តាំងមជ្ឈិម ស្នើឡើងគណៈលេខាពិនិត្យសម្រេច ។

- គណៈស្រាវជ្រាវប្រវត្តិសាស្ត្របក្ស ផ្អែកតាមសេចក្តីកំណត់នេះ កសាងបទវិន័យផ្ទៃក្នុង ការងាររបស់គណៈ និងបណ្តាអង្គភាពជំនួយការ សំដៅធានាឲ្យបានល្អនូវរាល់ភារកិច្ច ។

<u>**ប្រការ ៣**</u> : គណៈស្រាវជ្រាវប្រវត្តិសាស្ត្របក្ស ធ្វើការក្រោមការដឹកនាំរបស់គណៈកម្មាធិការមជ្ឈិមបក្ស ដោយផ្ទាល់ជាប្រចាំពីគណៈលេខា និងការិយាល័យនយោបាយមជ្ឈិមបក្ស ។

<u>**ប្រការ ៤**</u> : គណៈស្រាវជ្រាវប្រវត្តិសាស្ត្របក្ស ខុទ្ទកាល័យមជ្ឈិមបក្ស គណៈចាត់តាំងមជ្ឈិម បណ្តាគណៈរបស់បក្ស បណ្តាក្រសួង មន្ទីរ និងគណៈកម្មាធិការបក្សខេត្ត-ក្រុង ដែលទំនាក់ទំនងមានភារកិច្ចអនុវត្តតាមសេចក្តីសម្រេចនេះ ។

**ជ.ការិយាល័យនយោបាយមជ្ឈិមបក្ស**

ហត្ថលេខា និងត្រា **ហេង សំរិន**

---

**គណៈចាត់តាំងគណៈកម្មាធិការកណ្តាល**

លេខ: ១៥៤/២១ ចត.គក

ថ្ងៃអង្គារ ១២កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០២១

បានបម្លងត្រឹមត្រូវតាមច្បាប់ផ្លូវការ

**ប្រធានគណៈចាត់តាំង**

**សោម សឿន**